# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:......៦០ អនក្រ.បក

# អ នុ ក្រឹ ត្យ
## ស្តីពី
## អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលជាថ្មី នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលបានផ្តល់តាមខ្លឹមសារអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ នៅមានតំលៃប្រើប្រាស់រហូតដល់អស់សុពលភាព ។

**មាត្រា ២:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់សម្គាល់ខ្លួន ដើម្បីប្រើប្រាស់ក្នុងការបំពេញបែបបទរដ្ឋបាលផ្សេងៗ ឬដើម្បីអនុវត្តនីតិវិធីកាតព្វកិច្ចដទៃទៀត តាមច្បាប់បានកំណត់ ។

**មាត្រា ៣ :** មិនទាន់ត្រូវបានផ្តល់ ចំពោះជនទាំងឡាយដូចខាងក្រោម :

- កំពុងបំពេញជាបុព្វជិតក្នុងព្រះពុទ្ធសាសនា
- កំពុងអនុវត្តទោសតាមសាលក្រមរបស់តុលាការ
- កំពុងឋិតក្នុងមណ្ឌលអប់រំកែប្រែ
- វិកលចរិត
- ជនដែលមានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ ។

**មាត្រា ៤ :** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ ឆ្នាំ ចាប់ពីថ្ងៃចេញឱ្យប្រើប្រាស់ ។

**មាត្រា ៥ :** ពលរដ្ឋខ្មែរទាំងពីរភេទ មានកាតព្វកិច្ច មកធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងត្រូវសរសេរ ឬរាយឆ្លើយអំពីជីវប្រវត្តិផ្ទាល់ខ្លួន និង ឬត្រូវមាន :

- សំបុត្រកំណើតដែលបានបញ្ជាក់ថា សញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ (ក៤) ដែលបានបញ្ជាក់ពីសហព័ទ្ធសញ្ជាតិខ្មែរ ឬ
- សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា ជននោះកើតពីឪពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ ឬ
- ព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់សញ្ជាតិខ្មែរ តាមការទាមទារ ឬ សញ្ជាតូបនីយកម្មរបស់សាមីជន ឬ
- ឯកសារ ឬ ភស្តុតាងជាផ្លូវការ ដែលបញ្ជាក់ថា សាមីជនកើតមកពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ ។

**មាត្រា ៦ :** នីតិវិធី លក្ខណ្ឌក្នុងការសុំ ការផ្តល់ និង ការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៧ :** អភិបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវក្នុងការដឹកនាំ ចាត់តាំងអនុវត្ត ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៨ :** មន្ត្រីមានសមត្ថកិច្ច ដែលផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឱ្យដល់ជនដែលមិនមានសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់ស្តីពីសញ្ជាតិ ។

**មាត្រា ៩ :** ជនណាលួចផលិតក្លែងបន្លំ កោសលុប រាយការណ៍ ឬ សរសេរឈ្មោះមិនពិត ឬឱ្យគេខ្ចី ឬកាន់ប្រើប្រាស់អត្តសញ្ញាណប័ណ្ណក្លែងក្លាយ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់ស្តីពីសញ្ជាតិ ។

**មាត្រា ១០ :** ពលរដ្ឋ ដែលមកសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បឋមតា ទុតិយតា ត្រូវបង់អាករចូលថវិកាជាតិ ។ រយៈពេលចាប់ផ្តើម និងតម្លៃអត្តសញ្ញាណប័ណ្ណ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

**មាត្រា ១១ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពី អនុក្រឹត្យនេះ ទុកជានិរាករណ៍ ។

**មាត្រា ១២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**បានគោរពជូន**
**សម្តេចនាយករដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ- កាលប្បវត្តិ